# ការសម្ភាសរបស់ ចាន់ ធារិន

ក.អ្នកសម្ភាស ញ៉ែម សុគន្ធារី ខ. ចាន់ សារិន

ក. ចា៎! អញ្ចឹងអ៊ីលោកយាយ
តើអ៊ីឈ្មោះពេញរបស់លោកយាយនឹងមានឈ្មោះអ្វីដែរលោកយាយ?

ខ. ចាន់ ធារិន

ក. អញ្ចឹងលោកយាយមានឈ្មោះហៅក្រៅរឺក៏ឈ្មោះពីកុមារភាពអត់លោកយាយ?

ខ. ពីកុមារភាពម៉ោ?

ក. ចា៎ លោកយាយមានឈ្មោះហៅក្រៅអត់លោកយាយ?

ខ. អត់ទេ!

ក. ចុះឈ្មោះពីរកុមារភាពវិញ?

ខ. ហ្នឹង ចាន់ ធារិន ហ្នឹង!

ក. ឈ្មោះតែមួយនឹងលោកយាយ?

ខ. ចា៎!

ក. ចា៎! ចឹងលោកយាយតើលោកយាយធ្លាប់បានរៀនភាសាផ្សេងក្រៅពីភាសារខ្មែរអត់លោកយាយ?

ខ. អត់បានអត់បាន

ក. អត់ទេ!

ខ. អត់បានរៀនខ្មែរក៏អត់បានរៀនសាសនាក៏អត់បានរៀន។

ក. ចា៎! អញ្ចឹងសម្រាប់ភាសាខ្មែរវិញលោកយាយអត់បានរៀនទេ?

ខ. អត់បានរៀន

ក. ចា៎! អញ្ចឹងលោកយាយ តើទីកន្លែងកំណើតរបស់លោកយាយហ្នឹងនៅភូមិឃុំណាដែរលោកយាយ? ស្រុកកំណើតបស់លោកយាយ?

ខ. ភូមិ ដីឥដ្ឋ

ក. លោកយាយ តើចាប់រហូតដល់ពេលបច្ចុប្បន្នហ្នឹង តើលោកយាយមានអាយុប៉ុន្មានហើយលោកយាយ?

ខ. ម៉ាពាន់ប្រាំបួនរយ

ក. អាយុរបស់លោកយាយហ្អាស?

ខ. ចាំ!
ក. មានអាយុប៉ុន្មានហ្អើយលោកយាយ?
ខ. ៧៤
ក. ៧៤ឆ្នាំហ្អើយលោកយាយ?
ខ. ចាំ!
ក. អញ្ចឹងលោកយាយ តើលោកយាយបានចាំអំពីការរៀបអាពាហ៍ពិពាហ៍របស់លោកយាយ និង ស្វាមីរបស់លោកយាយហ្នឹងនៅឆ្នាំណាដែរលោកយាយអត់ចាំ?
ខ. ឆ្នាំម៉ានហ្អេស់ ៥០ម៉ានទេនៀក
ក. ចាំ! អត់អីលោកយាយ!

ខ. ហាសិបប្រាំពីរ
ក. ចាំ! ចាចអញ្ចឹងការរៀបការរបស់លោកយាយនឹងប្រព្រឹត្តទៅយ៉ាងដូចម្ដេចដែរលោកយាយ?
ខ. អត់អីទេ ខ្ញុំសុខសប្បាយរហូត។
ក. ចាំ! ចាំ អញ្ចឹងលោកយាយតើលោកយាយមានបងប្អូនប្រុសស្រីប៉ុន្មាននាក់ដែរលោកយាយ?
ខ. ច្រើនណាស់គាត់ងាប់អស់ហើយអត់ចាំគាត់ទេ។
ក. ចាំ! ចឹងនៅសស់តែលោកយាយមួយទេ?
ខ. សល់តែខ្ញុំមួយ
ក. ចាំ! អញ្ចឹងលោកយាយតើលោកយាយជាកូនទីប៉ុន្មានលោកយាយ?
ខ. ញ៉ុមកូនពៅគេ
ក. ចាំ!
ខ.បងខ្ញុំបង្អស់ទើបស្លាប់ក៏កូនបងដែរ។
ក. ចាំ!
ខ. គាត់មានកូនតែបីនាក់។
ក. ចាំ!
ខ. អាលូវខ្ញុំពៅគេ៧៤។
ក. ចាំ! អញ្ចឹង លោកយាយតើលោកយាយអាចនិយាយរៀបរាប់បន្តិចអំពីប្រវត្តិរបស់បងប្អូន

លោកយាយ តើលោកយាយអាចនិយាយបានអត់លោកយាយអាចនៅចាំខ្លះៗអំពីប្រវត្តិរបស់ពួកគាត់ ជីវភាពអីចឹងហ្អាស?
ខ. អត់ចាំទេ ចា៎!
ក. អត់ចាំ! អត់អី! លោកយាយចា៎អញ្ចឹងលោកយាយតើក្រុមគ្រួសារវីក៏បងប្អូនរបស់លោកយាយហ្នឹងគាត់ធ្លាប់ទៅរស់នៅឯក្រៅប្រទេសអត់លោកយាយ?
ខ. អត់អត់ទេ!
ក. គាត់នៅស្រុកខ្មែរហ្នឹងចា
ខនៅស្រុកខ្មែរ!
ក. អញ្ចឹង លោកយាយញ៉ុមសុំអត់ទោសលោកយាយដើម្បីសួរលោកយាយអំពីជីវិតរបស់លោកយាយតាំងពីកុមាររហូតដល់ពេលធំឡើងដល់ពេលបច្ចុប្បន្នហ្នឹង អញ្ចឹងលោកយាយមានជីវិតតស៊ូបែបណាដែរលោកយាយ?
ខ. ខ្ញុំតស៊ូប្រវត្តិខ្ញុំខ្ញុំដែលនៅម្ដាយមីងហ្អាសដែលនៅម្ដាយមីងនៅតិចទៅនៅបីឆ្នាំតិចទៅនៅប្រាំឆ្នាំ។
ក. ចា៎!
ខ. តិចនៅ៧ឆ្នាំគាត់ធ្វើការ រួចខ្ញុំនៅមួយជីដូនចាស់ហ្អាស។
ក. ចា៎!
ខញីញ៉ូវតាយាយតាខ្ញុំចាស់ៗហើយបើនៅអាយុជាង១០០ហ្អើយ
ក. ចា៎!
ខ. ប៉ុនមិនដឹង១០០ប៉ុន្មានអត់ចាំឆ្នាំកំណើតគាត់រួចពិបាកណាស់ប្រវត្តិខ្ញុំនិយាយទៅពិបាកជាងគេ គេគេស្រណុកខ្ញុំពិបាកគាត់ស្លាប់ ម្ដាយខ្ញុំស្លាប់ចោលតាំងខ្ញុំបាន៧ឆ្នាំ។
ក. ចា៎!
ខ. រួចគាត់ស្លាប់ចោលខ្ញុំនៅជាមួយជីដូនជីតាហ្នឹងអត់មានពីណាថៃ។
ក. ចា៎!
ខ. នៅមួយម្ដាយមីងគាត់រើសទៅចិញ្ចឹមពីរឆ្នាំបីឆ្នាំប្រាំឆ្នាំទម្រាំបានជីវិតប៉ុណ្ណឹង(សើច)។
ក. ចា៎! ចឹងលោកយាយតើលោកយាយនៅពេលដែលលោកយាយបានជួបជាមួយស្វាមីរបស់លោកយាយហ្នឹង តើលោកយាយបានជួបគាត់ដោយរបៀបណាដែរលោកយាយ?
ខ. គាត់ស្ដីដណ្ដឹងការមកនៅហ្នឹងហ៊្នង។

ក. ចាំ!
ខ. អត់មានពិបាកទៅនៅឯណាទេ ប៉ុនយើងហាត់ធ្វើស្រូវ។
ក. ចាំ!
ខ. អ្នកចម្ការ (សើច)
ក. ចាំ!
ខ. ធ្វើស្រូវធ្វើអង្ករដល់ខ្ញុំអត់បានធ្វើស្រូវកូនចៅវាពិបាក។
ក. ចាំ!
ខ. កម្លាំងចាស់ទៅធ្វើស្រូវលែងកើត។
ក. ចាំ! អញ្ចឹងលោកយាយតើលោកយាយធ្លាប់បានធ្វើការលោកយាយធ្វើការចម្ការ តើលោកយាយមានបានធ្វើការអ្វីផ្សេងទៀតក្រៅពីការធ្វើចម្ការហ្នឹងអត់?
ខ. អត់អត់ទេ អត់បានទេ បានតែធ្វើចម្ការហើយនិងលក់ដូរ។
ក. តិចតួចលោកយាយ?
ខ. ចាំ!
ក. ចាំ! អញ្ចឹងលោកយាយតើលោកយាយអាចប្រៀបធៀបអំពីជីវិតរបស់លោកយាយពេលនៅកុមារភាព និងពេលលោកយាយមកដល់បច្ចុប្បន្នហ្នឹង តើលោកយាយមានភាពខុសគ្នាយ៉ាងម៉េចដែរលោកយាយ?

ខ. សព្វថ្ងៃបានស្រណុកហើយ!
ក. ចាំ!
ខ. កូនចៅគេអោយញ៉ាំបាយម្ហូបអាហារគេបរិបូរណ៍។
ក. ចាំ!
ខ. ពីមុនពិបាកណាស់!
ក. ចាំ!
ខ. នៅកាលនៅក្មេងហាត់នឿយជីដូនជីតាចាស់ៗគាត់រកអីមានអត់ហើយអស់ប៉ុណ្ណឹង។
ក. ចាំ! អញ្ចឹងលោកយាយតើនៅពេលដែលជំនាន់ដែលលោកយាយរស់នៅជាមួយក្រុមគ្រួសាររបស់លោកយាយហ្នឹង តើផ្ទះរបស់លោកយាយហ្នឹង ជាផ្ទះអ្វីដែរលោកយាយ?
ខ. ផ្ទះធំចឹងដែរហ្អាក

ក. ទះឈើ?
ខ. ផ្ទះមុនក៏ធំ ផ្ទះឈើចឹងដែរប៉ុនគ្រាន់ប្រកស្បូវ
ក. ចំា! អញ្ចឹងលោកយាយ លោកយាយធ្លាប់បានឆ្លងកាត់ពេលសម័យប៉ុលពតអត់លោកយាយ?
ខ. ឆ្លង។
ក. ចំា ចឹងតើលោកយាយអាចរៀបរាប់អំពីសម័យហ្នឹងកាលពិបាករបស់លោកយាយដែលលោកយាយស្ថិតនៅសម័យហ្នឹង តើលោកយាយអាចរៀបរាប់ប្រាប់ញ៉ុមបានអត់លោកយាយ? វាពិបាកយ៉ាងមិចដែរ?
ខពិបាក គេអោយខ្ញុំជម្លៀសទៅក្រចេះ។
ក. ចំា!
ខ. ទៅកូនប្រាំប្រាំមួយនឹងទៅស្ពាយកូនចៅទៅហ្អាស
ក. ចំា!
ខ. ដល់រួចទៅរត់លិចកើតបែកកូនបែកចៅអស់
ក. ចំា!
ខពីខ្លួនដល់រួចខ្ញុំអត់អោយទៅដល់ចប់គេគេយកម៉ោបង្ហាញខ្ញុំថាលែងអោយទៅលែងអោយទៅគេថាអឹមម៉ែគេអោយទៅវិញទេអត់អោយទៅហ្អេសអញ់អត់អោយទៅគេទុកអោយវិញម៉ោ
ក. ចា អញ្ចឹងអឺលោកយាយពេលជនាន់នឹងតើគេបានប្រើលោកយាយអោយធ្វើការអីដែរលោកយាយ?
ខ. ធ្វើការស្ទូងដកដូចគ្នាហ្នឹង!
ក. ចំា!
ខ. តែជាន់អង្ករតែគាត់ងងឹតភ្នែកគេអោយជាន់អង្ករ
ក. ចំា!
ខ. រួចខ្ញុំធ្វើសេដ្ឋកិច្ចបាយ
ក. ចា តើពេលនឹងលោកយាយពិបាកមិចទៅនៅពេលសម័យហ្នឹងលោកយាយ?
ខ. ពិបាកដែរនាង មិនស្រណុកទេតិច តិចស្ទះខ្លួនខ្ញុំហ្អា។
ក. ចំា!
ខ. តិចៗស្ទះ តិចៗស្ទះអត់មានធ្វើអីច្រើន ប៉ុនណាគឺថាស្ទះហ្មង។

ក. ចាំ! លោកយាយមានជម្ងឺ?
ខ. ចាំ ចាំ!

ក. អញ្ចឹង លោកយាយតើលោកយាយចូលចិត្តបទចំរៀងអ្វីដែរលោកយាយ?
ខ. អត់ផងចអីក៏ខ្ញុំអត់ចេះ(សើច)
ក. អត់ចូលចិត្តទេហ្អេ? ចាំ!
ខអត់ចេះ កូនៗវាចេះទាំងអស់
ក. ចុះលោកយាយចូលចិត្តស្តាប់បទចម្រៀងអីចឹងហ្អាសចូលចិត្តអត់លោកយាយ?
ខអត់អត់ទេស!
ក. ចាំ! អញ្ចឹងលោកយាយតើម្ហូបដែលលោកយាយចូលចិត្តពិសា និងជាម្ហូបអីទៅលោកយាយ?
ខ. ស្អីក៏ញ៉ុមហូបដែរ។
ក. ចាំ!
ខ. ញ៉ុមអត់រើសទេ សម្លម្ជូរ ស្លប្រហើរ ស្លកកូរ អីចេះហូបទាំងអស់។
ក. ចាំ!
ខ. ចាំ!
ក. ចាំ! អញ្ចឹងលោកយាយនៅពេលដែលលោកយាយនៅយុវវ័យ តើលោកយាយចូលចិត្តលេង ចូលចិត្តជាហ្គេមរឺក៏ល្បែងប្រពៃណីបែបណា?
ខ. អត់អត់!
ក. អត់ចូលចិត្តទេ?
ខ. អត់ចូលចិត្តទេព្រោះអីមិនចេះតែម្តង។
ក. ចាំ!
ខ. មិនចេះលេង (សើច)
ក. ចាំ ចាំ(សើច) អញ្ចឹងលោកយាយ តើលោកយាយអាចប្រាប់ខ្ញុំបន្ថែមទៀតអំពីពេលវេលាដ៏លំបាកនៅក្នុងជីវិតលោកយាយហ្នឹង តើជាអ្វីទៅដែលលោកយាយគិតថាវាពិបាកបំផុតនៅក្នុងជីវិតលោកយាយ?
ខ. ពិបាកបំផុតគឺថាស្ទូងដកហ្នឹងហើយ ចង់ធ្វើហ្អាស។

ក. ចា៎!

ខ. អោយបានច្រើនហាត់ពេកទៅឈប់ទៅហើយធ្វើតែម្នាក់ឯងកូនចៅទៅរៀនអស់អស់

ក. ចា៎!

ខ. រួចខ្ញុំស្ទូងដកសំណាបស្ទូងអីចឹងទៅថ្ងៃណាទំនេរគេទៅជួយទៅ។

ក. ចា៎!

ខ. ហាត់រកប្រដូចបានទេ!

ក. ចា៎! អញ្ចឹងលោកយាយ តើលោកយាយអាចប្រាប់បន្ថែមទៀតអំពីបទការពិបាកមួយហ្នឹង តើលោកយាយបានឆ្លងកាត់វាដោយរបៀបណា?

ខ. ឆ្លងកាត់ដោយធ្វើ...

ក. ទើបវាលែងធ្វើអោយលោកយាយពិបាកអីចឹងណាស់លោកយាយ។

ខ. អាលូវកូនចៅបានគេអោយស្រណុកស្រួលគេមិនអោយធ្វើអី។

ក. ចា៎!

ខ. តាំងពីខ្ញុំធ្វើផ្ទះហ្នឹងមកកូនគេអត់អោយធ្វើ អីឈប់ធ្វើម៉ាក់ឯង

ក. ចា៎!

ខ. គេរកចិញ្ចឹមម្តង។

ក. ចា៎!

ខ. តែប៉ុណ្ណឹង!

ក. ចា៎! អញ្ចឹងលោកយាយតើលោកយាយអាចបង្ហាញអំពីបទពិសោធន៍ដ៏ល្អបំផុត ដែលមាននៅក្នុងជីវិតលោកយាយដែលលោកយាយបានចាំ តើវាជាបទពិសោធន៍អីទៅលោកយាយដែលល្អបំផុត?

ខ. ល្អបំផុត!

ក. បទពិសោធន៍លោកយាយ?

ខអត់មាន!

ក. អត់មានបទពិសោធន៍ទេ?

ខអត់មានទេ មានតែប៉ុណ្ណឹង។

ក. ចា៎!

ខ. អាក្រក់ក៏ប៉ុណ្ណឹង ល្អក៏ប៉ុណ្ណឹង (សើច)

ក. ចាំ!ចឹងលោកយាយ តើលោកយាយដែលមានបំណងប្រាថ្នារឺក៏...រឺក៏លោកយាយដែលលោកយាយគិតថាលោកយាយនៅពេលធំឡើងលោកយាយចង់ធ្វើអ្វីរឺក៏មានបំណងប្រាថ្នាអ្វីដែលលោកយាយគិតថាដែលលោកយាយបានប៉ងតាំងពីតូចមកលោកយាយ?

ខ. អត់មានប៉ងអត់មានប៉ងទាំងអស់ខ្ញុំធ្វើអីក៏ចេះតែធ្វើ។

ក. ចាំ!

ខ. ធ្វើស្លងដកអីក៏ខ្ញុំចេះតែធ្វើហើយការងារអីក៏ខ្ញុំចេះតែធ្វើលក់ដូរអីក៏ញ៉ុមធ្វើជ្រក់ស្ពៃអីធ្វើទាំងអស់(សើច)

ក. ចាំ! អញ្ចឹងលោកយាយការរៀបអាពាហ៍ពិពាហ៍រឺក៏ការមានកូនចៅ តើលោកយាយសង្ឃឹមថារឺក៏លោកយាយតែងស្រមើស្រម៉ៃថាលោកយាយនឹងមានក្រុមគ្រួសារដ៏ល្អមួយអត់លោកយាយ?

ខ. ខ្ញុំស្រមើស្រម៉ៃតែនឹកឃើញថាខ្ញុំធ្វើល្អ

ក. ចាំ!

ខ. កូនមុខតែធ្វើល្អដែរហ្អើយ!

ក. ចាំ!

ខ. ចាំ! តែប៉ុណ្ណឹងអត់មាននឹកអីទាំងអស់។

ក. ចាំ! អញ្ចឹងលោកយាយ ចឹងញ៉ុមអរគុណលោកយាយហ្អាសសម្រាប់អោយ...សម្រាប់លោកយាយដែលអនុញ្ញាតដើម្បីអោយញ៉ុមសម្ភាសលោកយាយ អញ្ចឹងលោកយាយតើលោកយាយមានចំណាប់អារម្មណ៍នឹងគិតដូចម្ដេចចំពោះបទសម្ភាសរបស់សាកលវិទ្យាល័យ ប៊ីវ៉ាយយូ លោកយាយ?

ខ. ដឹងសម្ភាសម៉េចទេ! (សើច)

ក. លោកយាយគិតថាវាល្អសម្រាប់លោកយាយរបៀបណាអីចឹងហ្អាសលោកយាយ?

ខ. មិនដឹងទេសព្វថ្ងៃនឹងល្អហ្អើយនៀក។

ក. ចាំ! ចុះលោកយាយគិតថាវាល្អអត់ការសម្ភាសន៍មួយហ្នឹងលោកយាយ?

ខ. ល្អហ្អាស់! រាល់ថ្ងៃធ្វើអីទេស្រណុកមែនទែន។ (សើច)

ក. ចាំ!

ខ. កូនគេមិនអោយធ្វើអី ធ្វើអីគេមិនអោយធ្វើដែរ ចង់ចាក់នំលក់អីក៏គេអត់អោយចាក់ នៅស្ងៀមទាំងអស់ ដាំបាយស៊ី ហីដាំបាយហើយធ្វើម្ហូបស៊ីទៅ និងដេក។ (សើច)

ក. ចាំ ចាំ! អញ្ចឹងលោកយាយការសម្ភាសមួយហ្នឹងលោកយាយគិតថាវាល្អអត់លោកយាយ?
ខ. ល្អ!

ក. ចាំ! អញ្ចឹងលោកយាយចឹងញ៉ុមសុំអនុញ្ញាតលោកយាយដើម្បីធ្វើការថតរូបភាពរបស់លោកយាយខ្លះៗហ្មាស។
ខ. ចាំ!
ក. អញ្ចឹងលោកយាយអនុញ្ញាតដើម្បីអោយញ៉ុមថតបានអត់លោកយាយ?
ខ. ថតទៅ!
ក. ចាំ! ចឹងអរគុណលោកយាយច្រើនសម្រាប់ការសម្ភាសមួយហ្នឹងលោកយាយ! អរគុណលោកយាយ!
ខ. ចាំ!

*កត់ដោយគង់រី